JICA កម្ពុជា

គម្រោងពង្រឹងប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាល

The Project for Strengthening Human Resources Development System of Co-medicals

ព្រឹត្តិប័ត្រព័ត៌មានពីគម្រោង HRD-JICA | លេខ ៥ | ខែវិច្ឆិកា ឆ្នាំ ២០១០

# ពិធីបើកសន្និសិទជាតិគិលានុបដ្ឋាក-យិកា និងឆ្មបលើកទី៤

សន្និសិទ្ធជាតិគិលានុបដ្ឋាក-យិកា និងឆ្មបលើកទី៤ បានប្រព្រឹត្តទៅកាលពីថ្ងៃទី ១៦ និង ១៧ ខែវិច្ឆិកានៅសណ្ឋាគារភ្នំពេញ។ តទៅនេះយើងសូមដកស្រង់ចំណាប់អារម្មណ៍របស់អ្នកជំនាញការ Noriko ដែលបានចូលរួមក្នុងសន្និសិទនេះ ដូចតទៅ :

## សន្ទរកថានៃរដ្ឋមន្ត្រីក្រសួងសុខាភិបាលក្នុងពិធីបើកសន្និសិទ

ក្នុងពិធិបើកសិន្និសិទជាតិគិលានុបដ្ឋាក-យិកា និងឆ្មបលើកទី៤ ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានលើកឡើងអំពីឥរិយាបថ ដែល-រួមមានគុណធមិ និង សីលធមិមានសារៈសំខាន់ក្រៃលែងក្នុងការប្រណិបត្តិវិជ្ជាជីវៈនេះ។

ក្រៅពីនេះ ការបង្កើតឱ្យមានច្បាប់ និង បទដ្ឋានសម្រាប់គិលានុបដ្ឋាក-យិកា និងឆ្មប នាពេលខាង-មុខនេះ នឹងជួយធានាឱ្យបាននូវការគោរពចំពោះតួនាទីក្នុងវិជ្ជា ជីវៈពីសំនាក់បុគ្គលិកសុខាភិបាល។

ការលើកឡើងអំពីការបង្កើតឱ្យមានច្បាប់និង បទដ្ឋានក្នុងឱកាសការបើកពិធីសន្និសិទនេះចូលរួមចំនែកក្នុងការផ្សព្វផ្សាយដល់អ្នកដែលប្រកបវិជ្ជាជីវៈនេះ និងស្ថាប័នដែលជាប់ពាក់ព័ន្ធដែលនឹងជួយឱ្យគម្រោងដំណើរការទៅមុខយ៉ាងរលូន និង មានប្រសិទ្ធភាព។

## ប្រធានបទ

ពិធីសិន្នសិទលើកទី៤ដែលប្រព្រឹត្តទៅនាឆ្នាំនេះគឺក្រោមប្រធានបទ "ការលើកកំពស់ស្វ័យភាពនៃសមត្ថភាពវិជ្ជាជីវៈនៃគិលានុបដ្ឋាក-យិកា និងឆ្មប ដើម្បីពង្រឹងគុណភាពនៃការថែទាំ "។ ទោះបីជាប្រធានបទបានលើកឡើងអំពី ការពង្រឹងគុណភាពនៃការថែទាំ ប៉ុន្តែជាទូទៅនៅតែមានការយល់ឃើញផ្សេងៗ គ្នាអំពីអត្ថន័យនៃការថែទាំ។

ថ្មីៗនេះ ពាក្យថា " សមត្ថភាព" និង "ស្វ័យភាព" ដែលជាពាក្យនៅក្នុងប្រធានបទកំពុងទទួល បាននូវប្រជាប្រិយភាពជាអន្តរជាតិ ក៏ដូចជានៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែយើងមិនទាន់ដឹងច្បាស់ថា តើគេទាំងអស់គ្នាយល់ច្បាស់អំពីអត្ថន័យដើមនៃពាក្យនេះដែរឬទេ? ដូច្នេះហើយយើងមានអារម្មណ៍ថា មានការយល់ឃើញខុសគ្នា ចំពោះការប្រើប្រាស់ ពាក្យនេះក្នុងវិស័យថែទាំ។ ប្រសិនបើនិយមន័យនៃពាក្យថែទាំ ក៏ដូចជាមុខងារ និង តួនាទីនៃការថែទាំមិនទាន់បានកំណត់ច្បាស់ទេ នោះគឺមិនអាចមានសមត្ថភាព ស្វ័យភាព និង ការថែទាំបាន ឡើយ។

## ទិដ្ឋភាពទាំងមូលនៃសន្និសិទ

សកម្មភាពទូទៅនៃសន្និសិទបានបង្ហាញ អំពីការគ្រប់គ្រងនៃមន្ទីរពេទ្យ និង មណ្ឌលសុខភាព ការ-រាយការណ៍និងផ្តល់ព័ត៌មាន វិធីសាស្ត្រនៃការថែទាំ ការបង្ការការឆ្លង និង ការផ្តល់ការបណ្តុះបណ្តាលបន្ថែមចំពោះបុគ្គលិកឆ្មប និង គិលានុបដ្ឋាក-យិកា ហើយក្នុងនោះរួមមានការគាំទ្រពីសំនាក់អង្គការក្រៅរដ្ឋាភិបាលផងដែរ។ យើងក៏សង្កេតឃើញមានការចូលរួមសួរជាសំណួរ និងការចែករំលែកបទពិសោធន៍យ៉ាងសកម្មពីសំណាក់អ្នកចូលរួម។





ទិដ្ឋភាពនៃសន្និសិទ

សូមទៅកាន់គេហទំព័រដែលមានអាស័យដ្ឋានដូចខាងក្រោមនេះ :

http://www.jica.go.jp/project/cambodia/004/index.html

# ការប្រៀបធៀបច្បាប់នានាដែលពាក់ព័ន្ធ

ចាប់ពីពេលនេះទៅ គំរោងនិងធ្វើការរៀបចំច្បាប់ដែលពាក់ពន្ធ័និងគិលានុបដ្ឋាកក្នុងប្រទេសកម្ពុជា។ ជាទូទៅ នៅពេលដែលធ្វើការនៅកន្លែង គេសឹងតែមិនគិតអំពីច្បាប់។ ប៉ុន្តែនៅប្រទេសជប៉ុន មានច្បាប់គិលានុបដ្ឋាកសុខភាពសាធារណ: គិលានុបដ្ឋាក និង ឆ្មប ដែលបានអនុម័តនៅឆ្នាំ ២៣ នៃសម័យ Showa និង ហៅថា [Hojokanho] ហើយបានក្លាយជាកាតព្វកិច្ច និង ជាគុណវឌ្ឍ។ អជ្ញាប័ណ្ណ ការប្រលងថ្នាក់ជាតិ និង កាតព្វកិច្ច ត្រូវបានចែងក្នុងច្បាប់នេះ។ ម៉្យាងវិញទៀត យើងសូមណែនាំនូវតារាងខាងក្រោម ដែលទាក់ទងទៅនឹងបច្ចុប្បន្នភាពនៃច្បាប់នៅក្នុងប្រជាជាតិអាស៊ាន។

| | កម្ពុជា | ថៃ | ឡាវ | ជប៉ុន |
|---|---|---|---|---|
| ប្រពន្ធ័ច្បាប់និងបទដ្ឋាន | មិនមាន | ច្បាប់វិជ្ជាជីវៈឆ្មប និង គិលានុដ្ឋាក (1985) | ច្បាប់ ឆ្មប និង គិលានុដ្ឋាន (2007) | ច្បាប់ស្តីពីគិលានុបដ្ឋាកសុខភាពសាធារណ: ឆ្មប និង គិលានុបដ្ឋាក（1948) |
| ស្ថាប័នអបរំ សំរាប់គិលានុបដ្ឋាន | បរិញ្ញាប័ត្ររង（3ឆ្នាំ）、បរិញ្ញាប័ត្រ（4ឆ្នាំ） | បរិញ្ញាប័ត្រ（4ឆ្នាំ） | បរិញ្ញាប័ត្ររង（3ឆ្នាំ） | នានា（3—4 ឆ្នាំ） |
| សញ្ញាប័ត្រ និង អជ្ញាប័ណ្ណ | មិនមានប្រពន្ធ័អជ្ញាប័ណ្ណទេ។ ប្រសិនបើគេបានបញ្ចប់ដូចក្នុងកម្មវិធីសិក្សា និង ប្រលងជាប់ គេជាគិលានុដ្ឋាក។ | អជ្ញាប័ណ្ណ | មិនមានប្រពន្ធ័អជ្ញាប័ណ្ណទេ។ ប្រសិនបើគេបានបញ្ចប់ដូចក្នុងកម្មវិធីសិក្សា និង ប្រលងជាប់ គេអាចធ្វើការជាគិលានុដ្ឋាក។ | អជ្ញាប័ណ្ណ |





ឆ្វេង៖ និស្សិតសាលាថែទាំនៃប្រទេសកម្ពុជា
ខាងលើ៖ និស្សិតសាលាថែទាំនៃប្រទេសឡាវ

## ការប្រៀបធៀបជាមួយប្រទេសជិតខាង

ប្រទេសកម្ពុជាជាប្រទេសដែលមានព្រំប្រទល់ជាប់ប្រទេស ថៃ ឡាវ និង វៀតណាម។ នៅព្រឹត្តិប័ត្រលេខនេះយើងសូមណែនាំអំពីពត៌មានទូទៅខ្លះរវាងកម្ពុជានិង ប្រទេសជិតខាង។




## ពត៌មានទូទៅ

## ផែនទីក្រុម



| | កម្ពុជា | ថៃ | វៀតណាម | ឡាវ | ជប៉ុន |
|---|---|---|---|---|---|
| ផ្ទៃដី (គម$^2$) | 181,035 | 514,000 | 329,241 | 240,000 | 377,914 |
| ចំនួនប្រជាជន (លាននាក់) | 1,340 (ស្ថិតិឆ្នាំ 2008) | 6,338 (ចុងឆ្នាំ 2008) | 8,579 (ជំរឿនឆ្នាំ២០០៩ ខែ៤ ថ្ងៃទី១) | 640 (ចំនួនប៉ាន់ប្រមាណដោយ IMF ឆ្នាំ ២០០៩ ) | 12,728 (2008) |
| ចំនួនប្រជាជនក្នុងក្រុង និង ជីប្រជុំជន (លាននាក់) | 132 (ភ្នំពេញ) ទិន្នន័យឆ្នាំ ២០០៩ | 825 (បាងកក) ទិន្នន័យឆ្នាំ ២០១០ | 235 (ហាណូយ) 778 (ហូជីមិញ) ទិន្នន័យឆ្នាំ ២០១០ | 70 (វៀងចន្ទ័) ទិន្នន័យឆ្នាំ ២០០៥ | 3,520 (តូក្យូ) ទិន្នន័យឆ្នាំ ២០១០ |
| ផលិតផលជាតិសរុបសំរាប់១នាក់ | 774 US$ (ឯកសាររដ្ឋាភិបាល កម្ពុជា ឆ្នាំ ២០០៨) | 3,923 US$ (ឆ្នាំ ២០០៩) | 1,064 US$ (ឆ្នាំ ២០០៩) | 878 US$ (ចំនួនប៉ាន់ប្រមាណដោយ IMF ឆ្នាំ ២០០៩ ) | 34,115 US$ (ឆ្នាំ ២០០៨) |
| ទង់ជាតិ | មានរូបអង្គរវត្តនៅកណ្តាល។ ពណ៌ខៀវ ផ្នែកខាងលើនិងក្រោមដំណាងឲ្យរាជវង្ស ពណ៌ក្រហមនៅកណ្តាលដំណាងអោយប្រជាជន និង អង្គរវត្តពណ៌ស ដំណាងឲ្យព្រះពុទ្ធសាសនា។ | ពណ៌ខៀវនៅកណ្តាលដំណាងអោយរាជវង្ស ពណ៌ស ដំណាងឲ្យព្រះពុទ្ធិសាសនា និង ពណ៌ក្រហម ដំណាងអោយការរួបរួមជាតិ និង ប្រជា។ | ពណ៌ក្រហមដំណាងឲ្យឈាមដែលបានបង្ហូរក្នុងបដិវត្តន៏ ផ្កាយពណ៌លឿងដំណាងឲ្យ កម្មករ យុវជន និង ទាហ៊ាន។ | ពណ៌ក្រហមដំណាងឲ្យឈាមដើម្បីសេរីភាព និង សន្តិភាព ពណ៌ខៀវដំណាងអោយឧត្តមភាពជាតិ និង ទន្លេមេគង្គ រង្វង់មូលពណ៌សមានន័យថាសន្តិភាព និង អនាគតភ្លឺស្វាង | មានការពន្យល់នានាជាច្រើន។ |

ឯកសារយោង : គេហទំព័រក្រសួងការបរទេស http://www.mofa.go.jp/mofaj/area/index.html Wikipedia 「ជប៉ុន」 Wikipedia 「ការប្រៀបធៀបចំនួនប្រជាជនពិភពលោក」 (ប្រជាសាស្ត្រ 2010)、Wikipedia 「ភ្នំពេញ」、Wikipedia 「វៀងចន្ទ័」

# ទំនាក់ទំនងសុខាភិបាលអន្តរជាតិ

    

| | កម្ពុជា | ថៃ | វៀតណាម | ឡាវ | ជប៉ុន | |
|---|---|---|---|---|---|---|
| អាយុមធ្យម (ក្នុងចំណោមប្រទេស ១៩៣) | 62<br>(142) | 70<br>(102) | 73<br>(71) | 62<br>(142) | 83<br>(1) | អាយុជាមធ្យមលើភិភពលោកគឺ បុរសមានអាយុ ៦៦ឆ្នាំស្ត្រី ៧០ឆ្នាំ អាយុមធ្យមបុរសស្ត្រី ៦៨ឆ្នាំ។ ស្ថិតិនេះ ជាស្ថិតិដែលមានប្រទេសចំនួន ១៩៣ ដែលជាសមាជិកអង្គការសុខភាពពិភពលោក (WHO) |
| អត្រាកំណើតស្លាប់ (ក្នុងចំណោមប្រទេស ១៩៣) | 31<br>(44) | 10<br>(108) | 9<br>(112) | 20<br>(64) | 1<br>(189) | ទារកទើបនិងកើតគឺ ទារកក្រោយកើតមានអាយុមិនទាន់ បាន១ខែ ៊ អត្រាកំណើតស្លាប់ ចំនួនស្លាប់ក្នុងកំណើត ១០០០នាក់។ អត្រាកំណើតស្លាប់ជាមធ្យមលើពិភពលោក គឺ ក្នុង ១០០០នាក់ មាន ២៦នាក់។ ស្ថិតិនេះ ជាស្ថិតិដែលមានប្រទេសចំនួន ១៩៣ ដែលជាសមាជិកអង្គការសុខភាពពិភពលោក(WHO) |
| អត្រាកំណើតពិសេសសរុប (ក្នុងចំណោមប្រទេស ១៩៣) | 2.9<br>(70) | 1.8<br>(139) | 2.1<br>(112) | 3.5<br>(52) | 1.3<br>(180) | អត្រាកំណើតពិសេសសរុប គឺជាចំនួនដែលស្ត្រីម្នាក់បង្កើតកូន។ អត្រាកំណើតពិសេសសរុប លើពិភពលោកគឺ ២.៥នាក់។ ស្ថិតិនេះ ជាស្ថិតិដែលមានប្រទេសចំនួន ១៩៣ ដែលជាសមាជិកអង្គការសុខភាពពិភពលោក (WHO) |
| សមាមាត្រប្រជាជនអាយុក្រោម ១៥ឆ្នាំ (ក្នុងចំណោមប្រទេស ១៩៣) | 34<br>(67) | 22<br>(135) | 27<br>(107) | 38<br>(49) | 13<br>(192) | សមាមាត្រប្រជាជនអាយុក្រោម ១៥ឆ្នាំ គឺជាអនុបាតចំពោះប្រជាជនអាយុក្រោម ១៥ឆ្នាំ ដែលធ្វើក្នុងចំនួនប្រជាជនសរុបនៃប្រទេសនិមួយៗ។ មធ្យមភាគលើពិភពលោកគឺ ២៧% ប្រទេសជប៉ុន ១៣% ដែលស្ថិតនៅក្នុងលំដាប់ទាបជាងគេ និង ក្លាយជាសង្គមដែលមានក្មេងតិចក្នុងគ្រួសារ និង មានមនុស្សចាស់ច្រើន។ ស្ថិតិនេះ ជាស្ថិតិដែលមានប្រទេសចំនួន ១៩៣ ដែលជាសមាជិកអង្គការសុខភាពពិភពលោក (WHO) |
| សមមាត្រចំនួនមនុស្សចាស់ដែលមានអាយុច្រើនជាង ៦០ឆ្នាំ (ក្នុងចំណោមប្រទេស ១៩៣) | 6<br>(116) | 1 1<br>(64) | 9<br>(75) | 5<br>(142) | 29<br>(1) | សមាមាត្រចំនួនមនុស្សចាស់ដែលមានអាយុច្រើនជាង ៦០ឆ្នាំគឺជាអនុបាតចំពោះប្រជាជនសរុបនៃប្រទេសនីមួយៗដែលមានអាយុលើសពី ៦០ឆ្នាំ។ ចំនួនជាមធ្យមលើពិភពលោកគឺ ១១% និង ប្រទេសជប៉ុនស្ថិតនៅលំដាប់ថ្នាក់ទី ១ ដែលមានចំនួនមនុស្សចាស់ច្រើន។ ស្ថិតិនេះ ជាស្ថិតិដែលមានប្រទេសចំនួន ១៩៣ ដែលជាសមាជិកអង្គការសុខភាពពិភពលោក (WHO) |
| ការប្រើប្រាស់នៃការឲ្យប្រសើរឡើងនៃធនធានទឹក (%)ក្នុងចំណោមប្រទេស ១៩៣) | 61<br>(147) | 98<br>(57) | 94<br>(76) | 57<br>(154) | 100<br>(1) | ការប្រើប្រាស់ធនធានទឹកដែលបានកែលំអមានន័យថាការប្រើប្រាស់ទឹកស្អាត។ មធ្យមភាគលើពិភពលោកគឺ ៨៧%។ ស្ថិតិនេះ ជាស្ថិតិដែលមានប្រទេសចំនួន ១៩៣ ដែលជាសមាជិកអង្គការសុខភាពពិភពលោក (WHO) |